## របៀបដាក់ពាក្យស្នើសុំ និងប្រើប្រាស់

# អត្ថប្រយោជន៍នៃអាហារមូលដ្ឋាន



Washington State Department of Social & Health Services

*Transforming lives*

DSHS 22-297 CA (Rev. 4/20) Cambodian

# មាតិកា


សេចក្តីផ្តើម ..................................................1

**ការដាក់ពាក្យស្នើសុំអាហារមូលដ្ឋាន**

តើខ្ញុំអាចទទួលបានអាហារមូលដ្ឋាន? ......................2

តើខ្ញុំដាក់ពាក្យស្នើសុំអាហារមូលដ្ឋានដោយរបៀបណា? .....2

តើនឹងមានអ្វីកើតឡើងបន្ទាប់ពីខ្ញុំប្រគល់ពាក្យស្នើសុំរបស់ខ្ញុំរួចហើយ? ...............................3

តើខ្ញុំគួរយកអ្វីខ្លះទៅសម្ភាស? .............................4

តើនឹងមានអ្វីកើតឡើងប្រសិនបើមានការប្រែប្រួលនានាចំពោះកាលៈទេសៈនានានៃគ្រួសាររបស់ខ្ញុំ? .......................5

ប្រសិនបើខ្ញុំមានសិទ្ធិទទួលបាន តើខ្ញុំនឹងទទួលបានអត្ថប្រយោជន៍អាហាររបស់ខ្ញុំនៅពេលណា?...............6

តើខ្ញុំនឹងទទួលបានអាហារមូលដ្ឋានក្នុងរយៈពេលយូរប៉ុណ្ណា? ...7

តើក្រសួងមានគោលនយោបាយមិនរើសអើងដែរឬទេ? .......8

**ការប្រើប្រាស់អត្ថប្រយោជន៍នៃអាហារមូលដ្ឋាន**

តើប័ណ្ណ Washington EBT QUEST គឺជាអ្វី? ...8

តើ EBT PIN គឺជាអ្វី?................................9

តើអ្នកកាន់ប័ណ្ណជំនួសគឺជាអ្វី? ............................9

តើខ្ញុំគួរហៅទូរសព្ទទៅកាន់សេវាអតិថិជន EBT នៅពេលណា? ................................ 10

តើខ្ញុំអាច និងមិនអាចធ្វើអ្វីបានខ្លះជាមួយប័ណ្ណ EBT និងអត្ថប្រយោជន៍នានា? ......................... 11

សំណួរ និងចម្លើយអំពី EBT ដែលត្រូវបានសួរជាញឹកញាប់ ..................................... 13

# [illegible]

អាហារមូលដ្ឋាន (ត្រូវបានស្គាល់នៅក្នុងសហព័ន្ធថាជា កម្មវិធីជំនួយ អាហារូបត្ថម្ភបន្ថែម ឬ SNAP) ជួយដល់ប្រជាជននៅក្នុងការទិញ គ្រឿងទេស។

ចំនួនទឹកប្រាក់នៃអាហារមូលដ្ឋានដែលអ្នកអាចទទួលបានគឺផ្អែកលើ ទំហំគ្រួសារ ប្រាក់ចំណូលដែលអាចរាប់បាន និងចំណាយប្រចាំខែ របស់អ្នក ដូចជា ការស្នាក់នៅ សេវាសាធារណៈ ការទំនុកបម្រុងកូន និងសោហ៊ុយផ្នែកវេជ្ជសាស្ត្រ។

សម្រាប់ការប៉ាន់ស្មានអំពីចំនួនទឹកប្រាក់នៃអាហារមូលដ្ឋានប្រចាំខែ ដែលអ្នកអាចទទួលបាន សូមហៅទូរសព្ទដោយឥតគិតថ្លៃទៅកាន់ 1-877-501-2233។



**នៅពេលដែលអ្នកទទួលបានអាហារមូលដ្ឋាន អ្នកអាចមានលក្ខណៈ សម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធីផ្សេងៗទៀត ដូចជា ៖**

- កម្មវិធីម្ហូបអាហារនៅសាលារៀនដោយឥតគិតថ្លៃ ឬមានការបញ្ចុះ តម្លៃ
- កម្មវិធីអាហារូបត្ថម្ភពិសេសសម្រាប់ស្ត្រី ទារក និងកុមារ (WIC)

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម ឬមានសំណួរដាក់លាក់នានាអំពី ស្ថានភាពរបស់អ្នក សូមហៅទូរសព្ទទៅកាន់ 1-877-501-2233 ឬចូលទៅកាន់វេបសាយត៍របស់យើងនៅ www.washingtonconnection.org/home/

## តើខ្ញុំអាចទទួលបានម្ហូបអាហារមូលដ្ឋានដែរទេ?

## អ្នកប្រហែលជាអាច បើអ្នក ៖

- រស់នៅក្នុងរដ្ឋវ៉ាស៊ីងតោន
- មានប្រាក់ចំណូលក្រោម 200% នៃកម្រិតភាពក្រីក្ររបស់សហព័ន្ធ
- បំពេញតាមលក្ខខណ្ឌតម្រូវនៃភាពជាពលរដ្ឋ ឬស្ថានភាពរបស់ ជនបរទេស

## តើអ្នកណាខ្លះដែលមិនអាចទទួលបានអាហារមូលដ្ឋាន?

- ឧក្រិដ្ឋជនរត់គេចខ្លួន
- ជនបរទេសដែលគ្មានឯកសារ

អាចមានលក្ខខណ្ឌតម្រូវផ្សេងទៀត ផ្អែកតាមស្ថានភាពគ្រួសាររបស់ អ្នក។

## តើខ្ញុំដាក់ពាក្យស្នើសុំអាហារមូលដ្ឋានដោយរបៀបណា?

មានវិធីចំនួនបួននៅក្នុងការដាក់ពាក្យស្នើសុំអាហារមូលដ្ឋាន ៖

- នៅលើបណ្តាញ នៅ www.washingtonconnection.org
- តាមទូរស័ព្ទ ដោយមិនដាក់ស្នើពាក្យសុំមួយ ដោយការហៅទូរស័ព្ទទៅលេខ 1-877-501-2233
- តាមរយៈការជួបដោយផ្ទាល់ នៅការិយាល័យសេវាសហគមរបស់ DSHS នៅក្នុងមូលដ្ឋាន។ ស្វែងរក CSO ដែលនៅជិតអ្នកបំផុតនៅ .
  www.dshs.wa.gov/office-locations
- តាមសំបុត្រ ៖

  DSHS Customer Service Center<br>
  PO Box 11699<br>
  Tacoma, WA 98411-6699

អ្នកអាចស្នើសុំពាក្យស្នើសុំជាក្រដាសមួយច្បាប់តាមរយៈការហៅ ទូរសព្ទទៅកាន់ 1-877-501-2233.

បំពេញ និងប្រគល់ពាក្យស្នើសុំរបស់អ្នកឲបានឆាប់រហ័សបំផុតតាម ដែលអ្នកអាចធ្វើបាន។ ប្រសិនបើអ្នកមានលក្ខណ:សម្បត្តិគ្រប់គ្រាន់ អត្ថប្រយោជន៍របស់អ្នកចាប់ផ្តើមពីកាលបរិច្ឆេទដែលអ្នកប្រគល់ ពាក្យស្នើសុំរបស់អ្នក។ យើងនឹងដំណើរការការស្នើសុំរបស់អ្នកនៅក្នុង រយ:ពេល 30 ថ្ងៃ។

# តើនឹងមានអ្វីកើតឡើងបន្ទាប់ពីខ្ញុំប្រគល់ពាក្យស្នើសុំរបស់ខ្ញុំរួចហើយ?



នៅពេលដែលយើងទទួលបានពាក្យស្នើសុំរបស់អ្នក អ្នកនឹងទទួលបាន ការសម្ភាសមួយដើម្បីធានាថា យើងយល់អំពីព័ត៌មាននៅលើ ពាក្យស្នើសុំនោះ។ បទសម្ភាសនានាត្រូវបានធ្វើឡើងតាមទូរសព្ទ ឬ នៅការិយាល័យសេវាសហគមរបស់ DSHS នៅក្នុងមូលដ្ឋានរបស់ អ្នក។

**ក្នុងអំឡុងពេលសម្ភាស យើងនឹង ៖**

- ពន្យល់អំពីវិធានរបស់កម្មវិធី
- សួរអ្នកនូវសំណួរនានាអំពីព័ត៌មាននៅលើពាក្យស្នើសុំរបស់អ្នក
- ស្នើសុំភ័ស្តុតាងបញ្ជាក់អំពីព័ត៌មានមួយចំនួនពីអ្នក
- ផ្តល់ជូនអ្នកនូវសំណៅចម្លងមួយច្បាប់នៃសិទ្ធិ និងទំនួលខុសត្រូវរបស់អ្នក
- ពន្យល់អំពីគោលបំណង ការប្រើប្រាស់យ៉ាងសមស្រប និងការដាក់ ពិន័យចំពោះការប្រើប្រាស់កម្មវិធីអាហារមូលដ្ឋានមិនបានត្រឹមត្រូវ
- ពន្យល់អំពីចំណុចណាមួយដែលអ្នកមិនយល់។

ប្រសិនបើអ្នកត្រូវការជំនួយចំពោះដំណើរការសម្ភាស អ្នកណាម្នាក់ ដែលដឹងអំពីកាលៈទេសៈរបស់អ្នកអាចដាក់ពាក្យស្នើសុំ និងទទួលការ សម្ភាសតាងនាមឲអ្នក។ មនុស្សម្នាក់នេះត្រូវបានហៅថាជាតំណាង មានការអនុញ្ញាត។

# តើខ្ញុំគួរយកអ្វីខ្លះទៅសម្ភាស?

**អ្នកត្រូវតែផ្តល់ជូននូវភ័ស្តុតាងបញ្ជាក់អំពី ៖**

- អត្តសញ្ញាណរបស់អ្នក
- ប្រាក់ចំណូលនៅក្នុងគ្រួសារ
- ស្ថានភាពអន្តោប្រវេសន៍របស់សមាជិកគ្រួសារណាម្នាក់ដែលមិនមែន ជាពលរដ្ឋ ដែលរួមបញ្ចូលទាំងព័ត៌មានអំពីប្រាក់ចំណូល និងធនធាន របស់អ្នកធានាផងដែរ ប្រសិនបើមាន។

**យើងក៏អាចស្នើសុំឲអ្នកផ្តល់ជូននូវភ័ស្តុតាងបញ្ជាក់អំពីព័ត៌មាន ណាមួយដែលមិនច្បាស់ផងដែរ។**

បន្ទាប់ពីសម្ភាសរួចរាល់ហើយ អ្នកនឹងទទួលបានលិខិតមួយច្បាប់ដែល រៀបរាប់អំពីនូវភ័ស្តុតាងណាមួយដែលយើងនៅតែត្រូវការដដែល។ យើងនឹងជួយ អ្នកនៅក្នុងការទទួលបានភ័ស្តុតាងនៃចំណុចនានាដែល យើងត្រូវការនៅក្នុង អំឡុងពេលនៃការសម្ភាសរបស់អ្នក។ អ្នកនឹងមាន រយៈពេលយ៉ាងតិច10ថ្ងៃនៅក្នុងការផ្តល់ភ័ស្តុតាងនោះ។



## តើនឹងមានអ្វីកើតឡើងប្រសិនបើមានការប្រែប្រួលនានាចំពោះកាលៈទេសៈនានានៃគ្រួសាររបស់ខ្ញុំ?

ប្រសិនបើគ្រួសាររបស់អ្នកទទួលបានតែអាហារមូលដ្ឋានទេនោះ អ្នក ចាំបាច់ត្រូវតែប្រាប់យើង ប្រសិនបើប្រាក់ចំណូលដុលសរុបនៃគ្រួសារ របស់អ្នកមានចំនួនលើសពី 130% នៃគោលការណ៍ណែនាំអំពីភាព ក្រីក្ររបស់សហព័ន្ធ។ អ្នកអាចប្រាប់យើងអំពីការប្រែប្រួលជាលាយ លក្ខណ៍អក្សរ តាមទូរសព្ទ តាមរយៈការជួបដោយផ្ទាល់ ឬនៅលើ បណ្ដាញនៅ www.washingtonconnection.org.

សម្រាប់ការសរសេរ អាសយដ្ឋាន

DSHS-CSD Customer Service Center
PO Box 11699
Tacoma WA 98411-6699

តាមទូរស័ព្ទ ៖ 1-877-501-2233

អ្នកត្រូវតែរាយការណ៍អំពីការប្រែប្រួលឲបានមុនថ្ងៃទីដប់នៃខែ បន្ទាប់ពីខែប្រាក់ចំណូលរបស់អ្នកបានកើនឡើងនោះ។ ឧទាហរណ៍ ៖ ប្រសិនបើអ្នកមានការប្រែប្រួលណាមួយដែលបានកើតឡើងនៅថ្ងៃនេះ នោះ អ្នកត្រូវតែរាយការណ៍ឲបានមុនថ្ងៃទីដប់នៃខែបន្ទាប់។

| មនុស្សនៅក្នុងគ្រួសារ | រាយការណ៍ បើសិនប្រាក់ចំណូលដល់ពេលបញ្ចប់ |
|---|---|
| 1 | $1,354 |
| 2 | $1,832 |
| 3 | $2,311 |
| 4 | $2,790 |
| 5 | $3,269 |



ប្រសិនបើគ្រួសាររបស់អ្នកទទួលបានអត្ថប្រយោជន៍ផ្សេងទៀតបន្ថែម ពីលើអាហារមូលដ្ឋាននោះ អ្នកត្រូវតែរាយការណ៍ស្របតាមលេខកូដ រដ្ឋបាលវ៉ាងស៊ីងតោន 388-418-0005។

អ្នកនឹងទទួលបានព័ត៌មានជាលាយលក្ខណ៍អក្សរអំពីរបៀបដែលការ ប្រែប្រួលនេះមានផលប៉ះពាល់ចំពោះអត្ថប្រយោជន៍អាហាររបស់អ្នក។ ប្រសិនបើអ្នកមិនយល់ស្របទេនោះ អ្នកអាចនិយាយជាមួយបុគ្គលិក ដែលមានសិទ្ធិណាម្នាក់ អ្នកត្រួតពិនិត្យណាម្នាក់ ឬបុគ្គលិករដ្ឋបាលនៃ ការិយាល័យសេវាសហគម។ ប្រសិនបើអ្នកនៅតែមិនយល់ស្របទៀត នោះ អ្នកអាចស្នើសុំសវនការរដ្ឋបាលមួយបាន។

## ប្រសិនបើខ្ញុំមានសិទ្ធិទទួលបាន តើខ្ញុំនឹងទទួលបានអត្ថប្រយោជន៍អាហាររបស់ខ្ញុំនៅពេលណា?

នៅពេលដែលអ្នកដាក់ពាក្យស្នើសុំជាលើកទីមួយ អត្ថប្រយោជន៍របស់ អ្នកនឹងត្រូវបានចេញជូនបន្ទាប់ពីយើងទទួលបានព័ត៌មានទាំងអស់ដែល យើងត្រូវការដើម្បីធ្វើសេចក្តីសម្រេចថាតើអ្នកមានសិទ្ធិទទួលបានដែរឬទេ។

- ជាមធ្យម យើងអនុម័តលើពាក្យស្នើសុំសម្រាប់គ្រួសារដែលមានសិទ្ធិ ទទួលបាននៅក្នុងរយៈពេលប្រហែល 10 ថ្ងៃ។
- ជិតពាក់កណ្តាលនៃពាក្យស្នើសុំទាំងអស់ត្រូវបានអនុម័តនៅក្នុង រយៈពេលតិចជាងប្រាំមួយថ្ងៃ។

បន្ទាប់ពីទឹកប្រាក់អាហារមូលដ្ឋានដំបូងរបស់អ្នកត្រូវបានចេញជូនអ្នក ហើយនោះ ថ្ងៃនៃខែដែលអ្នកទទួលបានអាហារមូលដ្ឋានរបស់អ្នកនឹង មិនកែប្រែនោះទេ។ ថ្ងៃជាក់លាក់ដែលអត្ថប្រយោជន៍នៃអាហារ មូលដ្ឋានរបស់អ្នកអាចស្វែងរកបាន ត្រូវបានបោះពុម្ពនៅលើសេចក្តី ជូនដំណឹងអំពីការអនុម័តរបស់អ្នក។

អត្ថប្រយោជន៍របស់អ្នកអាចស្វែងរកបាននៅថ្ងៃចុងសប្តាហ៍ និងថ្ងៃ ឈប់សម្រាកហើយអត្ថប្រយោជន៍ណាមួយដែលអ្នកមិនបានចំណាយ ត្រឹមចុងខែនោះ ត្រូវបានយោងបន្តទៅខាងបន្ទាប់។



## តើខ្ញុំនឹងទទួលបានអាហារមូលដ្ឋានក្នុងរយៈពេលយូរប៉ុណ្ណា?

**នៅពេលដែលអ្នកមានសិទ្ធិទទួលបានសម្រាប់កម្មវិធីអាហារមូលដ្ឋាន អ្នកនឹងទទួលបានលិខិតមួយច្បាប់ពីយើង ដែលប្រាប់អ្នក ៖**

- ថាតើអ្នកមានសិទ្ធិទទួលបានដែរឬទេ
- តើរយៈពេលនៃការបញ្ជាក់របស់អ្នកមានចំនួនប៉ុន្មានខែ
- ចំនួនទឹកប្រាក់នៃអត្ថប្រយោជន៍អាហារដែលអ្នកនឹងទទួលបាន។

នៅពាក់កណ្ដាលផ្លូវនៃរយៈពេលនៃការបញ្ជាក់របស់អ្នក (ប្រាំមួយខែ សម្រាប់គ្រួសារភាគច្រើន) អ្នកនឹងទទួលបាន ការត្រួតពិនិត្យឡើងវិញ នៅពាក់កណ្ដាលរយៈពេលនៃការបញ្ជាក់មួយច្បាប់ ដើម្បីបំពេញ។ យើងនឹងប្រើប្រាស់របាយការណ៍នោះ ដើម្បីធ្វើបច្ចុប្បន្នកម្មព័ត៌មានរបស់ អ្នក មនុស្សនៅក្នុងផ្ទះរបស់អ្នក ប្រាក់ចំណូលនៃគ្រួសាររបស់អ្នក និង ចំណាយមួយចំនួន។ នេះដើម្បីធ្វើឲប្រាកដថា អ្នកកំពុងតែទទួលបាន ចំនួនទឹកប្រាក់នៃអត្ថប្រយោជន៍ដែលត្រឹមត្រូវ។ អ្នកក៏អាចបំពេញការត្រួតពិនិត្យឡើងវិញនោះតាមទូរសព្ទបានផងដែរ។

ក្នុងរយៈពេលប្រហែល 45 ថ្ងៃមុនពេលដែលអាហារមូលដ្ឋានរបស់អ្នក ត្រូវបានកំណត់ថាផុតកំណត់នោះ អ្នកនឹងទទួលបានសេចក្ដីជូនដំណឹង មួយច្បាប់រួមជាមួយទម្រង់នៃការត្រួតពិនិត្យឡើងវិញអំពីសិទ្ធិទទួលបាន ដើម្បីបំពេញ ប្រសិនបើអ្នកនៅតែមានបំណងទទួលបានអត្ថប្រយោជន៍ អាហារបន្តទៀតនោះ។

**បំពេញ និងប្រគល់ទម្រង់នៃការត្រួតពិនិត្យឡើងវិញអំពីសិទ្ធិទទួលបាន ជូន ៖**

DSHS Customer Service Center
PO Box 11699
Tacoma, WA 98411-6699

យើងនឹងផ្ញើសំបុត្រមួយច្បាប់ជូនអ្នកដើម្បីធ្វើបទសម្ភាសតាមទូរសព្ទ ឬនៅក្នុងការិយាល័យសេវាសហគមរបស់ DSHS នៅក្នុងមូលដ្ឋាន របស់អ្នក។ អ្នកត្រូវតែបញ្ចប់បទសម្ភាសនេះឲបានរួចរាល់ ដើម្បីស្វែងរកថាតើអ្នកមានសិទ្ធិទទួលបានអត្ថប្រយោជន៍អាហារ បន្ថែមទៀតដែរឬទេ។



## តើក្រសួងមានគោលនយោបាយមិនរើសអើងដែរឬទេ?

ស្របតាមច្បាប់សហព័ន្ធ និងគោលនយោបាយរបស់ក្រសួងកសិកម្ម នៃសហរដ្ឋអាមេរិក ស្ថាប័ននេះត្រូវបានហាមឃាត់ពីការរើសអើង ដោយផ្អែកលើមូលដ្ឋាននៃជាតិសាសន៍ ពណ៌សម្បុរ សញ្ជាតិដើម ភេទ អាយុ សាសនា ជំនឿផ្នែកនយោបាយ ឬពិការភាពនោះទេ។

### ដើម្បីដាក់ពាក្យបណ្ដឹងអំពីការរើសអើងណាមួយ សូមសរសេរ ៖

USDA, Director, Office of Civil Rights
1400 Independence Ave. SW
Washington, D.C. 20250-9410

ឬហៅទូរសព្ទទៅកាន់ 1-800-795-3272 (សម្លេង) ឬ 1-202-720-6382 (TTY). USDA គឺជាអ្នកផ្ដល់ឱកាសស្មើគ្នា និងជានិយោជក។

## តើប័ណ្ណ Washington EBT QUEST គឺជាអ្វី?

ប្រព័ន្ធរបស់ប័ណ្ណអត្ថប្រយោជន៍តាមប្រព័ន្ធអេឡិចត្រូនិច (EBT) មាន សុវត្ថិភាព មានភាពងាយស្រួល និងជាវិធីដ៏ងាយស្រួលមួយសម្រាប់ អ្នកនៅក្នុងការទទួលបានអត្ថប្រយោជន៍អាហាររបស់អ្នកនៅក្នុងខែ នីមួយៗ។

- អ្នកត្រូវតែប្រើប្រាស់ប័ណ្ណនេះដើម្បីទទួលបានអត្ថប្រយោជន៍របស់អ្នក។
- ប័ណ្ណនេះដំណើរការប្រហាក់ប្រហែលគ្នានឹងប័ណ្ណ ATM ដែរ ប៉ុន្តែអត្ថប្រយោជន៍អាហារនៅលើប័ណ្ណនោះអាចប្រើប្រាស់បានដើម្បី ទិញអាហារតែប៉ុណ្ណោះ។
- អត្ថប្រយោជន៍របស់អ្នកនឹងត្រូវបានដាក់នៅក្នុងគណនីមួយដែលត្រូវ បានបង្កើតឡើងសម្រាប់អ្នក។
- អត្ថប្រយោជន៍របស់អ្នកអាចប្រើប្រាស់បានតែជាមួយលេខអត្តសញ្ញាណ ផ្ទាល់ខ្លួន (PIN) ដែលសម្ងាត់របស់អ្នកប៉ុណ្ណោះ



## តើ EBT PIN គឺជាអ្វី?

គ្រប់ពេលដែលអ្នកប្រើប្រាស់ប័ណ្ណរបស់អ្នក អ្នកត្រូវតែបញ្ចូលលេខ សម្ងាត់ បួន ខ្ទង់។ លេខសម្ងាត់ទាំងនេះត្រូវបានហៅថា PIN (លេខអត្តសញ្ញាណផ្ទាល់ខ្លួន)

**** = PIN (លេខសម្ងាត់ 4 ខ្ទង់)

**ទាំងនេះគឺជាវិធីដើម្បីទទួលបាន PIN ៖**

- ប្រសិនបើអ្នកទទួលបានប័ណ្ណរបស់អ្នកនៅការិយាល័យ DSHS នៅក្នុងមូលដ្ឋានរបស់អ្នកនោះ អ្នកនឹងជ្រើសរើស PIN របស់អ្នក នៅពេលនោះ។
- ប្រសិនបើប័ណ្ណត្រូវបានផ្ញើទៅកាន់អ្នកតាមរយៈសំបុត្រនោះ - អ្នក ត្រូវតែហៅទូរសព្ទទៅកាន់សេវាអតិថិជនដើម្បីជ្រើសរើស PIN ថ្មី ឬផ្លាស់ប្តូរ PIN របស់អ្នកសារជាថ្មី។

ចូរកុំបោះវាចោល! អ្នកត្រូវការលេខទាំង បួន ខ្ទង់នេះ និងប័ណ្ណរបស់ អ្នកដើម្បីទទួលបានអត្ថប្រយោជន៍របស់អ្នក។

ចូរកុំសរសេរ PIN របស់អ្នកនៅលើប័ណ្ណរបស់អ្នក និងកុំចែករំលែក PIN របស់អ្នកជាមួយអ្នកណាម្នាក់ដែលមិនស្ថិតនៅក្នុងគ្រួសាររបស់ អ្នក! រក្សាទុក PIN របស់អ្នកនៅកន្លែងដែលមានសុវត្ថិភាព និងមិននៅក្នុងកាបូបលុយតែមួយជាមួយប័ណ្ណរបស់អ្នកឡើយ។

ប្រសិនបើអ្នកបាត់ប័ណ្ណរបស់អ្នក ឬ ប័ណ្ណរបស់អ្នកខូច PIN នៅតែល្អដូចដើម។ ប័ណ្ណជំនួសថ្មីមួយនឹងមាន PIN ដដែល។ PIN នឹងមិនកែប្រែឡើង លើកលែងតែអ្នកស្នើសុំឲកែប្រែវា។

## តើអ្នកកាន់ប័ណ្ណជំនួសគឺជាអ្វី?

អ្នកអាចជ្រើសរើសអ្នកណាម្នាក់ផ្សេងទៀតឲជួយអ្នកនៅក្នុងការ ប្រើប្រាស់អត្ថប្រយោជន៍របស់អ្នក។ បុគ្គលនេះត្រូវបានហៅថា អ្នកកាន់ប័ណ្ណជំនួស។

**អ្នកកាន់ប័ណ្ណជំនួស**

- ត្រូវបានជ្រើសរើសដោយអ្នក។
- នឹងទទួលបានប័ណ្ណ Washington QUEST និង PIN របស់ពួកគេផ្ទាល់នៅការិយាល័យ DSHS នៅក្នុងមូលដ្ឋាន
- នឹងអាចចំណាយអត្ថប្រយោជន៍របស់អ្នក។

ប្រសិនបើអ្នកជ្រើសរើសអ្នកណាម្នាក់ឲធ្វើជាអ្នកកាន់ប័ណ្ណជំនួសរបស់ អ្នក ចូរជ្រើសរើសមនុស្សម្នាក់ដែលអ្នកទុកចិត្ត។ ចូរចងចាំថា អត្ថប្រយោជន៍ដែលត្រូវបានបាត់បង់ ឬត្រូវបានលួចនឹងមិនត្រូវបាន ផ្លាស់ថ្មីជូននោះទេ។ សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីទទួលបានទម្រង់ នៃការអនុញ្ញាត សូមហៅទូរសព្ទទៅកាន់ 1-877-501-2233។

## តើខ្ញុំគួរហៅទូរសព្ទទៅកាន់សេវាអតិថិជន EBT នៅពេលណា?

សេវាអតិថិជន EBT

1-888-328-9271

លេខបញ្ជូនបន្តរបស់រដ្ឋ TTY

1-800-833-8388

លេខបញ្ជូនបន្តរបស់រដ្ឋ TTY នៃអក្សរសម្រាប់មនុស្សថ្លង់ងងឹតភ្នែក

1-800-833-6385

**ហៅទូរសព្ទដោយឥតគិតថ្លៃ 24 ម៉ោងក្នុងមួយថ្ងៃ និង ប្រាំពីរ ថ្ងៃក្នុងមួយសប្ដាហ៍ នៅពេលដែល ៖**

- អ្នកត្រូវការដឹងអំពីសមតុល្យនៅក្នុងគណនីអាហារ ឬគណនីសាច់ប្រាក់របស់អ្នក។
- ប័ណ្ណរបស់អ្នកបានបាត់ ត្រូវគេលួច ឬខូច។
- អ្នកមានបំណងស្ដាប់អំពីប្រតិបត្តិការចំនួន 10 លើកចុងក្រោយរបស់ អ្នកសម្រាប់គណនីសាច់ប្រាក់ ឬគណនីអាហាររបស់អ្នក។
- អ្នកចង់បានកាតជំនួសថ្មីមួយ ឬ PIN ថ្មីមួយតាមរយៈសំបុត្រ។

**តំណាងសេវាអតិថិជនក៏អាចជួយអ្នក ៖**

- ស្វែងរកកន្លែងមួយដែលនៅក្បែរកន្លែងដែលអ្នកអាចប្រើប្រាស់ប័ណ្ណ របស់អ្នកបានផងដែរ។
- ទទួលបានប្រវត្តិក្នុងរយៈពេល ពីរ ខែនៃប្រតិបត្តិការរបស់អ្នក។
- រាយការណ៍អំពីបញ្ហាទាទាចំពោះ ATMs។
- ប្រសិនបើអ្នកនិយាយភាសាណាមួយក្រៅពីភាសាអង់គ្លេស។

## តើខ្ញុំអាច និងមិនអាចធ្វើអ្វីបានខ្លះជាមួយប័ណ្ណ EBT និងអត្ថប្រយោជន៍នានា?

ការប្រើប្រាស់ប័ណ្ណ Washington QUEST របស់អ្នកមិនបាន ត្រឹមត្រូវ គឺជាបទឧក្រិដ្ឋរដ្ឋ និងសហព័ន្ធ!

### ការប្រើប្រាស់យ៉ាងសមស្រប

អ្នក ឬសមាជិកម្នាក់នៃគ្រួសាររបស់អ្នកអាចប្រើប្រាស់អត្ថប្រយោជន៍នៃអាហារ មូលដ្ឋានរបស់អ្នកដើម្បីទិញទំនិញជាអាហារ ដូចជា ៖

- នំប៉័ង និងគ្រាប់ធញ្ញជាតិនានា
- ផ្លែឈើ និងបន្លែនានា
- ឈីស ទឹកដោះគោ និងផលិតផលដែលផលិតពីទឹកដោះគោ ផ្សេងទៀត
- សាច់ ត្រី សាច់មាន់ និងស៊ុត
- ទំនិញជាអាហារភាគច្រើនផ្សេងទៀតដែលមិនត្រូវបានលក់ជាអាហារ ក្តៅដែលត្រៀមរួចជាស្រេច
- គ្រាប់ពូជ និងរុក្ខជាតិនានាដែលផលិតអាហារ

### ការប្រើប្រាស់ខុសច្បាប់

វាមិនស្របច្បាប់នោះទេ នៅក្នុងការ ៖

- ប្រើប្រាស់អត្ថប្រយោជន៍អាហារនានានៅលើប័ណ្ណ EBT របស់អ្នក សម្រាប់គោលបំណងណាមួយក្រៅពីការទិញអាហារសម្រាប់ សមាជិកគ្រួសារដែលមានសិទ្ធិទទួលបាន។
- ដោះដូរអត្ថប្រយោជន៍អាហាររបស់អ្នកជាមួយវត្ថុណាមួយដែលមាន តម្លៃ (ការជួញដូរ)។ ឧទាហរណ៍នានានៃការជួញដូរខុសច្បាប់រួមមាន ការដោះដូរអត្ថប្រយោជន៍អាហារជាមួយសាច់ប្រាក់ ឬវត្ថុណាមួយ ក្រៅពីការទិញអាហារពីអ្នកលក់រាយដែលមានការអនុញ្ញាតណាម្នាក់។
- ផ្តល់អត្ថប្រយោជន៍របស់អ្នកទៅឲ្យអ្នកណាម្នាក់ដែលមិនស្ថិតនៅក្នុង គ្រួសារនៃអាហារមូលដ្ឋានរបស់អ្នក។
- ប្រើប្រាស់អត្ថប្រយោជន៍នៃអាហារមូលដ្ឋានដើម្បីទិញវត្ថុដែលមិនមែន ជាអាហារ ដូចជា សម្ភារផ្គត់ផ្គង់នៅក្នុងគ្រួសារ វីតាមីន ឱសថ ចំណីសត្វ ថ្នាំជក់ ឬគ្រឿងស្រវឹង។



**ការដាក់ពិន័យចំពោះការប្រើប្រាស់ខុសច្បាប់។ អ្នកប្រហែលជាអាច ៖**

- ការដកសិទ្ធិ និងបាត់បង់អត្ថប្រយោជន៍របស់អ្នកក្នុងរយៈពេលយ៉ាងតិចមួយឆ្នាំ និងរហូតដល់មួយជីវិត។ ការដកសិទ្ធិនៅតែបន្តទោះបីជាអ្នកផ្លាស់ទៅកាន់រដ្ឋណាមួយផ្សេងទៀតក៏ដោយ។
- មានការពិន័យជាប្រាក់។
- មានចំណាត់ការតាមផ្លូវច្បាប់ ដែលរួមបញ្ចូលទាំងការដាក់បណ្ដឹងព្រហ្មទណ្ឌផងដែរ។ DSHS នឹងសហការជាមួយអាជ្ញាធរកាត់ក្ដីប្រចាំរដ្ឋ នៅក្នុងមូលដ្ឋាន និងសហព័ន្ធ ដើម្បីកាត់ទោសការជួញដូរអត្ថប្រយោជន៍នៃអាហារមូលដ្ឋាន ឬ SNAP។

## ប្រើប្រាស់អត្ថប្រយោជន៍របស់អ្នកឲបានទាន់ពេលវេលា

អត្ថប្រយោជន៍នានានៃជំនួយផ្នែកអាហាររបស់អ្នកមានបំណងបំពេញតាមតម្រូវការរបស់គ្រួសាររបស់អ្នកនាពេលបច្ចុប្បន្ន។

យើងអាចលុបចោលអាហារមូលដ្ឋាននៅក្នុងគណនីរបស់អ្នក ប្រសិនបើអ្នកមិនប្រើប្រាស់អត្ថប្រយោជន៍ណាមួយនៅក្នុងរយៈពេល 365 ថ្ងៃ។

## សំណួរ និងចម្លើយអំពី EBT ដែលត្រូវបានសួរជាញឹកញាប់

Q: តើអ្នកអាចប្រើប្រាស់ប័ណ្ណ EBT របស់អ្នកនៅខាងក្រៅរដ្ឋបានដែរឬទេ?

A: ប័ណ្ណ Washington QUEST ត្រូវបានទទួលយកនៅទូទាំង ប្រទេសនៅកន្លែងលក់រាយនានាដែលចូលរួមនៅក្នុងកម្មវិធី EBT. ស្វែងរកស្លាកសញ្ញា QUEST ឬត្រួតពិនិត្យជាមួយហាងមុនពេល ព្យាយាមប្រើប្រាស់ប័ណ្ណ QUEST របស់អ្នក។ ហាងនានាដែលលក់ អាហាររអាច ឬអាចមិនចូលរួមក្នុងនាមជាអ្នកផ្តល់អត្ថប្រយោជន៍ សាច់ប្រាក់។

Q: តើអ្នកអាចប្រគល់ជូនវិញនូវការទិញណាមួយដែលត្រូវបានធ្វើឡើងជាមួយប័ណ្ណរបស់អ្នកបានដែរឬទេ?

A: បាទ/ចាស បាទ! ឧទាហរណ៍ ៖ ប្រសិនបើទឹកដោះគោដែលអ្នកទើបតែ ទិញបានខូច អ្នកអាចនាំយកទឹកដោះគោដែលខូចនោះ និងបង្កាន់ដៃ បង់ប្រាក់ត្រឡប់ទៅកាន់ហាងនោះវិញបាន។ គណនីអាហាររបស់អ្នក នឹងត្រូវបានកត់ត្រាឥណទានសម្រាប់ការប្រគល់ជូនវិញនោះ។ អ្នកនឹង មិនទទួលបានសាច់ប្រាក់សម្រាប់ការប្រគល់ជូនវិញនោះទេ ប្រសិនបើ វត្ថុនោះត្រូវបានទិញដោយប្រើប្រាស់អត្ថប្រយោជន៍អាហាររបស់អ្នក។

Q: តើអ្នកអាចទទួលបានសាច់ប្រាក់ត្រឡប់មកវិញសម្រាប់ អត្ថប្រយោជន៍អាហារនានានៅលើប័ណ្ណ EBT របស់ខ្ញុំដែរឬទេ?

A: ទេ។ អត្ថប្រយោជន៍អាហារណាមួយដែលអ្នកមិនបានប្រើប្រាស់នៅចុងខែ អាចស្វែងរកបាននៅក្នុងខែបន្ទាប់។

Q: ប្រសិនបើខ្ញុំផ្លាស់ទៅនៅខាងក្រៅរដ្ឋ តើខ្ញុំអាចបន្តទទួលបានអាហារមូលដ្ឋានទៀតដែរឬទេ?

A: អាហារមូលដ្ឋាន គឺសម្រាប់តែអ្នករស់នៅនៅក្នុងរដ្ឋវ៉ាស៊ីងតោនតែប៉ុណ្ណោះ។ អ្នកនឹងចាំបាច់ត្រូវហៅទូរសព្ទទៅកាន់មជ្ឈមណ្ឌលសេវាអតិថិជនតាមរយៈលេខ 1-877-501-2233 ដើម្បីបិទសំណុំរឿងរបស់អ្នក ធ្វើដូច្នេះអ្នកអាចដាក់ពាក្យស្នើសុំអត្ថប្រយោជន៍នានានៃកម្មវិធីជំនួយអាហារបំប៉នបន្ថែម (SNAP) នៅក្នុងរដ្ឋដែលអ្នករស់នៅនៅពេលនេះ។ អ្នកនៅតែអាចប្រើប្រាស់អត្ថប្រយោជន៍នានាដែលត្រូវបានចេញនៅលើប័ណ្ណ EBT របស់អ្នកបានដដែល នៅខណៈពេលដែលអ្នករស់នៅនៅក្នុងរដ្ឋវ៉ាស៊ីងតោន។

USDA គឺជាអ្នកផ្តល់ឱកាសស្មើគ្នា ជានិយោជក និងជាអ្នកផ្តល់កម្ចី។
ស្ថាប័ននេះ គឺជាអ្នកផ្តល់ឱកាសស្មើគ្នា។

Take a Fresh Look
Basic Food

DSHS 22-297 CA (Rev. 4/20) Cambodian